# ការបែងចែកមត៌ក

ឧទ្ទេសនាមដោយ
លោកមេធាវី អ៊ីវ ប៉ូលី

១៥/មករា/២០១៨

# ការបែងចែកមតិក




ក្រ.រដ្ឋប្បវេណី

- បទបញ្ញត្តិទូទៅ (គន្ថី១)
- បុគ្គល (គន្ថី២)
- សិទ្ធិប្រត្យក្ស (គន្ថី៣)
- កាតព្វកិច្ច (គន្ថី៤)
- កិច្ចសន្យាសំខាន់ៗ (គន្ថី៥)
- ការធានាកាតព្វកិច្ច (គន្ថី៦)
- ញាតិ (គន្ថី៧)
- សន្តតិកម្ម (គន្ថី៨)
- អវសានប្បញ្ញត្តិ (គន្ថី៩)

# មាតិកា

ក. សញ្ញាណនៃសន្តតិកម្ម

១. សន្តតិជន

២. ចំណែកមត៌ក

ខ. ការរៀបចំបែងចែកមត៌ក

១. ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

២. ការបញ្ជាក់អំពីសន្តតិជន

៣. ការបញ្ជាក់អំពីកម្មវត្ថុនៃសន្តតិកម្ម

៤.ការបញ្ជាក់អំពីភាគពូកិច្ច

# មាតិកា

គ. ការអនុវត្តជាក់ស្តែងនៃការបែងចែកមត៌ក

១.លំហូរនៃការទទួលរឿងក្តីសន្តតិកម្ម

២.របៀបសរសេរពាក្យសុំបែងចែកមត៌ក

៣.ឯកសារភ្ជាប់

៤.មូលដ្ឋាននៃការវិនិច្ឆ័យ

៥.សេចក្តីសម្រេចបញ្ចប់

# ក. សញ្ញាណនៃសន្តតិកម្ម

សន្តតិកម្ម ចាប់ផ្តើមដោយសារមរណភាពរបស់មតកជន ហើយសន្តតិកម្មត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬដោយផ្អែកតាមឆន្ទៈរបស់មតកជន។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថាសន្តតិកម្មតាមច្បាប់ រីឯសន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជនហៅថាសន្តតិកម្មតាមមតកសាសន៍។

# ក. សញ្ញាណនៃសន្តតិកម្ម

សន្តតិកម្មចាប់ផ្តើមដោយសារមរណភាព
របស់មតកជន ហើយវាអាចជាសន្តតិកម្ម
តាមច្បាប់ ឬជាសន្តតិកម្មតាមមតកសាសន៍



# ១. សន្តតិជន

## ១.១ សន្តតិជនតាមច្បាប់

សន្តតិជនលំដាប់ទី១៖ កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬកូនសុំក្តី។ មួយវិញទៀតបើកូនរបស់មតកជនបានទទួលមរណភាព នៅមុន ឬព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬបាត់បង់សិទ្ធិសន្តតិកម្ម របបសន្តតិកម្មជំនួសនឹងត្រូវបានយកមកអនុវត្ត។

# ១. សន្តតិជន

ឪពុក ស្លាប់បាន
បន្សល់មត៌កឱ្យកូន

កូនរបស់មតកជនជា
សន្តតិជនលំដាប់ទី១





ឪពុក




កូន

# ១. សន្តតិជន

ថ្ងៃដែលA និងBស្លាប់ក្នុងគ្រោះថ្នាក់ចរាចរណ៍ជាមួយគ្នា

ដូចនេះ C ជាសន្តតិកម្មជំនួស





Aឪពុក



Bកូនរបស់A




Cកូនរបស់B

# ១. សន្តតិជន

**សន្តតិជនលំដាប់ទី២៖** ប្រសិនបើ មតកជន ពុំមានបច្ឆាញាតិផ្ទាល់នោះទេ បុព្វញាតិផ្ទាល់ ដូចជា ឪពុកម្តាយ ជីដូនជីតា ជាអាទិ៍ នឹងត្រូវទទួលបន្តមត៌កនោះ។

ដោយB គ្មានបច្ឆាញាតិផ្ទាល់នោះទ្រព្យរបស់ Bត្រូវធ្លាក់ទៅលើបុព្វញាតិផ្ទាល់B។

ដូចនេះ A ជាអ្នកទទួលនៅទ្រព្យសម្បត្តិនោះ។ A ជាសន្តតិជនលំដាប់ទី២។



Aឪពុក





Bកូនរបស់A

# ១. សន្តតិជន

**សន្តតិជនលំដាប់ទី៣៖** បើមតកជនគ្មានបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់នោះទេ បងប្អូនបង្កើតរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី៣។

A បានស្លាប់ហើយបានបន្សល់រថយន្ត១គ្រឿង ដោយ A មិនមានបុព្វញាតិផ្ទាល់ និងបច្ឆាញាតិផ្ទាល់។ ដូចនេះ រថយន្តនោះត្រូវធ្លាក់មក B ដែលជាបងប្អូនបង្កើតរបស់ A ត្រូវជាសន្តតិជនលំដាប់ទី៣








A ជាមតកជន

B ជាប្អូនបង្កើតរបស់A

# ១. សន្តតិជន

**សន្តតិជនជានិច្ច៖** សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច(មាត្រា ១១៦១.១)។

A មានឡាន និងផ្ទះដែលជាទ្រព្យរបស់ខ្លួន។




A

A និង Bជាសហព័ន្ធនឹងគ្នា



B




C កូន

B និង C ជាសន្តតិជន ដោយC ជាសន្តតិជនលំដាប់ទី១ ចំណែក B ជាសន្តតិជនជានិច្ច។



# ១. សន្តតិជន

## ១.២ អភ័ព្វបុគ្គលនៃសន្តតិកម្ម

អភ័ព្វបុគ្គល ជាជនគ្មានលក្ខណៈសម្បត្តិក្នុងការទទួលបាននូវសន្តតិកម្ម ដោយមានមូលហេតុដូចខាងក្រោម៖

**ក.** ទទួលទោស ដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតមតកជនឬអ្នកមានលំដាប់សន្តតិកម្មមុន ឬស្មើ ទោះបីដោយប្រយោល ឬដោយផ្ទាល់ក្តី

**ខ.** បុគ្គលដែលបានដឹងអំពីការសម្លាប់មតកជន ប៉ុន្តែមិនរាយការណ៍ ឬមិនប្តឹងលើកលែងតែបុគ្គល នោះមិនអាចវិនិច្ឆ័យល្អឬអាក្រក់ ឬអ្នកសម្លាប់ជាសហព័ទ្ធ ឬញាតិលោហិតខ្សែផ្ទាល់

# ១. សន្ដតិជន

**គ.** បុគ្គលដែលបានរារាំងមតកជន ក្នុងការលុបចោល ឬកែប្រែមតកសាសាន៍ ដោយឆបោក ឬគម្រាមកំហែង

**ឃ.** បុគ្គលដែលបានឱ្យមតកជនធ្វើ ឬលុបចោល ឬកែប្រែមតកសាសន៍ដោយឆបោក ឬគម្រាមកំហែង

**ង.** បុគ្គលដែលបានក្លែង កែបន្ថំ បំផ្លាញ ឬលាក់ទុកនូវមតកសាសន៍របស់មតកជន។

# ១. សន្តិជន

ករណី «ក»




ដោយ A បានសម្លាប់ឪពុករបស់ខ្លួនដូចនេះ A ត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឃាតកម្ម។

ដូចនេះ តាមក្រមរដ្ឋប្បវេណី A ក៏ជាអភ័ព្វបុគ្គលដែរ។



A

# ១. សន្តតិជន

## ១.៣ ការផ្តាច់មត៌កពីសន្តតិជន

ប្រសិនបើម្ចាស់ទ្រព្យ មានឆន្ទៈមិនប្រគល់ទ្រព្យសម្បត្តិឱ្យទៅសន្តតិជន នៅពេលខ្លួនទទួលមរណភាព ម្ចាស់ទ្រព្យអាចផ្តាច់មត៌កពីសន្តតិជន តាមផ្លូវតុលាការ ឬកំណត់ក្នុងមតកសាសន៍។

# ១. សន្តតិជន

**-តាមផ្លូវតុលាការ៖** ត្រូវដាក់ពាក្យសុំដីកាសម្រេចផ្តាច់មត៌កដោយភ្ជាប់ជាមួយនឹងមូលហេតុណាមួយដូចជា៖

ក. ធ្វើបាបមតកជន

ខ. ប្រមាថមតកជន

គ. អាចមើលថែទាំមតកជនបាន នៅពេលមានជម្ងឺ ប៉ុន្តែមិនមើលថែទាំ

ឃ. ទទួលបានសេចក្តីសម្រេចពីតុលាការ ដាក់ពន្ធនាគារមួយជីវិត

ង. ប្រព្រឹត្តអំពីល្មើសធ្ងន់ធ្ងរ គួរឱ្យកត់សំគាល់ ជាអាទ៍។

# ១. សន្តតិជន

ករណី«ក»



កូន បានវាយធ្វើបាបឪពុកក្នុងករណីនេះ ឪពុកអាចផ្តាច់មត៌កពីកូននោះបាន ដោយប្រើយន្តការតុលាការ។

ករណី«ខ»



កូន បានជេរប្រមាថឪពុកជាញឹកញាប់ករណីនេះ ឪពុកអាចផ្តាច់  មត៌កពីកូននោះបាន ដោយប្រើយន្តការតុលាការ។

# ១. សន្តតិជន

– តាមការកំណត់ក្នុងមតកសាសន៍៖ គឺម្ចាស់បណ្តាំបានធ្វើមតកសាសន៍ ផ្តាច់មត៌កពីសន្តតិជន អ្នកប្រតិបត្តិមតកសាសន៍ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជននោះនៅពេលដែលមតកសាសន៍នោះ បង្កើតអានុភាព។

# ១. សន្តតិជន

លិខិតបណ្តាំមានខ្លឹមសារថាផ្តាច់មត៌កពីសន្តតិជន




អ្នកប្រតិបត្តិមតកសាសន៍របស់មតកជន បានដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជននៅពេលមតកជនទទួលមរណភាព



មតកជន



អ្នកប្រតិបត្តិមតកសាសន៍

# ១. សន្តតិជន

ករណីសន្តតិជនមានសញ្ជាតិបរទេស និងសញ្ជាតិខ្មែរ




ករណីនេះ ដីបានទៅសន្តតិជនដែលមានសញ្ជាតិខ្មែរ។ ដូចនេះ មានសំនួរចោទឡើងថា តើសន្តតិជនដែលមានសញ្ជាតិបរទេសអាចទទួលបាននូវចំណែកជាមួយសន្តតិជនសញ្ជាតិខ្មែរដែរឬទេ?

# ១. សន្តតិជន

ករណីសន្តតិជនជនបរទេសទាំងអស់ហើយអាចលក់ដីក្នុងអំឡុងពេល០៣ខែ




សន្តតិជនដែលជាជនបរទេសមិនអាចមានសិទ្ធិលើដីទេ

⇓

ដូចនេះករណីដែលសន្តតិជនជាជនបរទេស នោះដីនឹងក្លាយជានីតិបុគ្គលមតិក

⇓

ហើយត្រូវលក់ដីនោះ ក្នុងអំឡុងពេល០៣ខែ គិតចាប់ពេលដែលសហសន្តតិជនទាំងអស់នោះយល់ព្រមជាឯកច្ឆ័ន

⇓

ចំណែកថ្លៃដែលលក់បានក្លាយជាមតិក នាំឱ្យនីតិបុគ្គលមតិកត្រូវរលត់។

# ១. សន្តតិជន

## ករណីសន្តតិជនមិនអាចលក់ក្នុងអំឡុងពេល០៣ខែ




ក្នុងករណីដែលសន្តតិជនលំដាប់ទី១មិនអាចចាត់ចែងក្នុងអំឡុងពេល ០៣ខែ ដូចនេះ កម្មសិទ្ធិនៃដីនោះនឹងត្រូវបានធ្លាក់ទៅសន្តតិជនដែលមានលំដាប់បន្ទាប់ដែលមានសញ្ជាតិខ្មែរ។

# ១. សន្តតិជន

## ១.៤ ការយល់ព្រមទទួល និងការបោះបង់សន្តតិកម្ម

សន្តតិជនត្រូវធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មទាំងស្រុង ឬដោយកម្រិតនៅក្នុងអំឡុងពេល០៣ ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើមដោយអំឡុងពេលនេះ អាចពន្យាពេលបាន តាមរយៈពាក្យសុំទៅតុលាការ ដើម្បីទុកលទ្ធភាពឱ្យសន្តតិជនធ្វើការស្រាវជ្រាវមតិកនៅមុនពេលបង្ហាញឆន្ទៈ យល់ព្រម ឬបោះបង់ (មាត្រា១២៤៨)។

**- ករណីពិសេសនៃអំឡុងពេលមានដូចជា៖**

# ១. សន្តតិជន

## ១. ការពន្យាពេលដោយតុលាការ(មាត្រា១២៤៨)

A មតកជន



A មានទ្រព្យ៖ ឡាន ផ្ទះ និងដី ហើយបាន សរសេរថា ទុកឱ្យ B បន្ទាប់ពីខ្លួនស្លាប់

B កូនរបស់ A



B ដាក់ពាក្យសុំទៅតុលការដើម្បីពន្យាពេល ក្នុងការស្រាវជ្រាវមត៌កមុនពេលយល់ព្រម ឬបោះបង់។

តុលាការ J



តុលាការអាចយល់ព្រមពន្យាពេលបើមានមូលហេតុសមរម្យ ដូចជា ទ្រព្យមានច្រើនប្រភេទ នៅទីតាំងផ្សេងៗគ្នា និងមានប្រតិបត្តិការច្រើន ជាអាទិ៍

# ១. សន្តតិជន

## ២. បើសន្តតិជនទទួលមរណភាព(មាត្រា១២៨៩)

A មតកជន



A មានទ្រព្យ៖ ឡាន ផ្ទះ និងដី ហើយបាន សរសេរថា ទុកឱ្យ B បន្ទាប់ពីខ្លួនស្លាប់

B កូនរបស់ A



B បានទទួលមរណភាពមុនពេលធ្វើការ យល់ព្រម ឬបោះបង់នៅក្នុងអំឡុងពេល ដែលច្បាប់បានកំណត់។

C កូនរបស់ B



ដូចនេះ មត៌កនឹងធ្លាក់ទៅ C ដែលជាសន្តតិជន របស់ B ហេតុនេះអំឡុងពេលត្រូវគិតចាប់ពីពេល ដែល C បានដឹងថាសន្តតិកម្មចាប់ផ្តើមចំពោះខ្លួន។

# ១. សន្តតិជន

## ៣. បើសន្តតិជនជាអនីតិជន ជាអាទិ៍ (មាត្រា ១២៥០)

A មតកជន



A មានទ្រព្យ៖ ឡាន ផ្ទះ និងដី ហើយបាន សរសេរថា ទុកឱ្យ B បន្ទាប់ពីខ្លួនស្លាប់

A កូនរបស់ B



ករណីដែលអនីតិជនជាសន្តតិជនបែបនេះ អំឡុងពេលនៃការយល់ព្រម ឬបោះបង់ គឺ ត្រូវគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់របស់ B បានដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះB។

# ១. សន្តតិជន

## ៤. បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច(មាត្រា ១២៥១)

A មតកជន



A ជាម្ចាស់ហាងពេជ្រដែលធំជាងគេមួយកន្លែងនៅក្នុងទីក្រុងភ្នំពេញ ហើយបើពេលខ្លួនស្លាប់ទៅ A នឹងទុកនៅហាងនោះឱ្យទៅកូន។ តែ A ក៏មានទ្រព្យអកម្មដ៏ច្រើនផងដែរ។

B កូន A



ក្នុងករណីនេះ ដោយ B មិនអាចដឹងថា A ជំពាក់បំណុលគេដ៏ច្រើនបែបនេះ ព្រោះតែគិតថាស្ថានភាពជំនួញរបស់ឪពុកខ្លួនធំ។ ដូចនេះ ការគិតអំឡុងពេលនៃការយល់ព្រម ឬបោះបង់ ត្រូវគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីបំណុលនោះ។

# ១. សន្តតិជន

(១) ការយល់ព្រមមាន០២គឺ៖

**-ការយល់ព្រមទាំងស្រុង៖** ក្នុងករណីដែលសន្តតិជនទទួលយល់ព្រមទាំងស្រុងនូវសន្តតិកម្ម មានន័យថា សន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន ដោយតម្រូវឱ្យបង្ហាញឆន្ទៈជាការគ្រប់គ្រាន់ មានន័យថា មិនចាំបាច់ដាក់ពាក្យសុំទៅតុលាការ ដូចករណីយល់ព្រមដោយកម្រិត ឬបោះបង់សន្តតិកម្មនោះឡើយ (មាត្រា ១២៥៤) ។

# ១. សន្តតិជន

A មាន ឡាន ផ្ទះ និង បំណុល ១០.០០០$ នៅពេលស្លាប់នឹងទុកឱ្យ B

B បានបង្ហាញឆន្ទៈថាខ្លួនយល់ព្រមទទួលមត៌កទាំងស្រុង នេះហៅថាការយល់ព្រមទាំងស្រុង



A មតកជន

បំណុល ១០.០០០$





B កូន A

# ១. សន្តតិជន

- **ការយល់ព្រមមានកម្រិត៖** ការយល់ព្រមដោយមានកម្រិត មានខ្លឹមសារថា ធ្វើសកម្មភាពនៃសន្តតិកម្មដែលបម្រុងសម្រាប់សងកាតព្វកិច្ចនឹងទទួលដោយសន្តតិកម្ម ត្រឹមកម្រិតទទួលដោយសន្តតិកម្ម មានន័យថាសន្តតិជនក្លាយទៅជាកូនបំណុល ដោយទទួលនូវសន្តតិកម្មនៃកាតព្វកិច្ចទាំងអស់របស់មតកជន ប៉ុន្តែសន្តតិជនអាចកម្រិតការទទួលខុសត្រូវបានត្រឹមកម្រិតនៃចំណែកមតិក លើកលែងសន្តតិជនសងកាតព្វកិច្ចដោយស្ម័គ្រចិត្ត (មាត្រា១២៥៦)។

# ១. សន្តតិជន

+ **វិធី៖** ដើម្បីធ្វើការយល់ព្រមដោយមានកម្រិត សន្តតិជនត្រូវដាក់ពាក្យសុំទៅតុលាការក្នុងអំឡុងពេល ០៣ខែ គិតចាប់ពីពេលដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះខ្លួន ប៉ុន្តែអំឡុងពេលនេះអាចពន្យាពេលបាន បើមានការអនុញ្ញាតពីតុលាការ តាមពាក្យសុំរបស់សាមីខ្លួន(មាត្រា១២៥៧)។

# ១. សន្តតិជន

**+ អានុភាព ៖** អានុភាពនៃការយល់ព្រមដោយកម្រិត ដែលមានខ្លឹមសារថា ម្ចាស់បំណុលរបស់មតកជន មិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជន នោះបានឡើយ(មាត្រា ១២៥៨)។

+ការយល់ព្រមដោយមានកម្រិតកើតឡើងមុនការយល់ព្រមតាមច្បាប់៖ សន្តតិជនយល់ព្រមដោយកម្រិត បើមានមូលហេតុដែលជាការទទួលខុសត្រូវទាំងតាមផ្លូវច្បាប់ ផលប្រយោជន៍នៃការយល់ព្រមដោយកម្រិតត្រូវបានបាត់បង់(មាត្រា១២៥៩)។

# ១. សន្តតិជន

A មាន ឡាន ផ្ទះ និង
បំណុល ១០.០០០$ នៅ
ពេលស្លាប់នឹងទុកឱ្យ B

B បានបង្ហាញឆន្ទៈថាខ្លួនយល់
ព្រមទទួលតែ ផ្ទះ និងបំណុល
៥.០០០$ ប៉ុណ្ណោះនេះ ហៅថា
ការយល់ព្រមដោយកម្រិត។



A មតកជន



B កូន A

# ១. សន្តតិជន

(២) ការបោះបង់ (មាត្រា១២៦០ មាត្រា១២៦១)

- **វិធី៖** បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំទៅតុលាការនៅក្នុងអំឡុងពេល ០៣ ខែ គិតចាប់ពីពេលដឹងថាសន្តតិកម្មចាប់ផ្ដើមចំពោះខ្លួនលើកលែងតែមានពាក្យសុំទៅតុលាការ ហើយតុលាការអនុញ្ញាត។

- **អានុភាព៖** បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះ មិនមែនជាសន្តតិជនតាំងពីដំបូងមក។

# ១. សន្តតិជន

A មាន ឡាន ផ្ទះ និង
បំណុល ១០០.០០០$ នៅ
ពេលស្លាប់នឹងទុកឱ្យ B

B បានដាក់ពាក្យសុំទៅ
តុលាការថាខ្លួនបោះបង់សន្តតិ
កម្មរបស់ A នេះហៅថា ការ
បោះបង់សន្តតិកម្ម។



A មតកជន



B កូន A

# ២. ចំណែកមត៌ក

## ២.១ ចំណែកសន្តតិកម្មតាមច្បាប់

- ករណីសន្តតិជន ជាកូន ចំណែកសន្តតិកម្មរបស់កូននីមួយៗ គឺស្មើភាគគ្នា(មាត្រា១១៥៦.២)។



# ២. ចំណែកមត៌ក

- ករណីមតកជនពុំមានបច្ចាញាតិផ្ទាល់ បុព្វញាតិផ្ទាល់របស់មតកជននឹងទទួលបានចំណែកមត៌កស្មើៗគ្នា(មាត្រា១១៥៩)។



# ២. ចំណែកមត៌ក

- ករណីមតកជនពុំមានបច្ចាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់ បើបងប្អូនបង្កើតរបស់មតកជនមានចំនួនច្រើននាក់នឹងទទួលបានចំណែកមត៌កស្មើៗគ្នា។ប៉ុន្តែចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាងនឹងទទួលបានចំណែកមត៌កតែ១/២នៃចំណែកមត៌ករបស់បងប្អូនបង្កើត ដែលមានឪពុកម្តាយទាំងសងខាងដូចគ្នា (មាត្រា១១៦០)។

# ២. ចំណែកមត៌ក



# ២. ចំណែកមត៌ក

ប្រសិនបើសហព័ទ្ធរបស់មតកជន និងបុគ្គលផ្សេងទៀតក្លាយជាសន្តតិជន ចំណែកមត៌កត្រូវធ្វើការបែកចែកដូចខាងក្រោម(មាត្រា១១៦២)៖

- **បើសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់** ជាសន្តតិជន នាំឱ្យទទួលចំណែកមត៌កស្មើៗគ្នា។



# ២. ចំណែកមត៌ក

- បើសហព័ទ្ធ និងឪពុក-ម្ដាយរបស់មតកជន ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធគឺ ១/៣ រីឯឪពុក-ម្ដាយគឺ២/៣។ ប៉ុន្តែបើឪពុក-ម្ដាយរបស់មតកជននៅរស់តែម្នាក់ ឪពុក ឬម្ដាយ ជាមួយនឹងសហព័ទ្ធនឹងទទួលបានចំណែកមត៌កស្មើៗគ្នា។



# ២. ចំណែកមត៌ក

- បើសហាព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុក-ម្ដាយ ឬបងប្អូនបង្កើត ឬអ្នកជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហាព័ទ្ធគឺ ១/២ រីឯបុគ្គលទាំងនោះគឺ១/២។



# ២. ចំណែកមត៌ក

## ២.២ ផលប្រយោជន៍ពិសេស(មាត្រា ១១៦៣)

ផលប្រយោជន៍ពិសេស ជាផលប្រយោជន៍ពិសេសដែលបុគ្គលណាម្នាក់ ឬច្រើននាក់ទទួលប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវិតរស់នៅ ឬដែលបានទទួលអច្ច័យទានពីមតកជន។

# ២. ចំណែកមត៌ក

- កម្មវត្ថុនៃការសម្រួលចំណែកមត៌ក៖ ជាគោលការណ៍ សន្តតិជនត្រូវទទួលបានចំណែកមត៌កស្មើៗគ្នា ប៉ុន្តែប្រសិនបើ មានជនដែលទទួលផលប្រយោជន៍ពិសេស ហើយយើងយកចំណែកមត៌កជាក់ស្តែង ជាកម្មនៃចំណែកនោះ ទៅសន្តតិជនទាំងអស់ ដោយមិនសម្រួលចំណែកមត៌ករបស់ជន ដែលមានផលប្រយោជន៍ពិសេស នាំឱ្យការបំពាននូវខ្លឹមសារថា សន្តតិជនទាំងអស់ត្រូវមានចំណែកស្មើៗគ្នា ដូចនេះក្រមរដ្ឋប្បវេណីបានបញ្ញត្តិអំពីចំណែកមត៌កនៃជនដែលទទួលផលប្រយោជន៍ពិសេសតាមវិធីនៃការសម្រួលចំណែក(មាត្រា១១៦៣ និងមាត្រា ១១៦៦)

# ២. ចំណែកមត៌ក

- **វិធីសម្រួលចំណែកមត៌ក៖** នៅក្នុងចំណោមសហាសន្តតិជនទាំងអស់មានសន្តតិជនណាម្នាក់ ឬច្រើននាក់បានទទួលនូវប្រទានកម្ម ឬអច្ច័យទានពីមតកជន តម្លៃសរុបនៃមត៌កត្រូវយកទ្រព្យរបស់មតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម បូកបញ្ចូលតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីការដកតម្លៃនៃប្រទានកម្ម ឬអច្ច័យទានចេញពីចំណែកមត៌ក គឺជាចំណែកមត៌ករបស់បុគ្គលនោះ(មាត្រា១១៦៣)។

# ២. ចំណែកមត៌ក

**រូបមន្ត៖** មត៌កសរុប= មត៌កពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស

$$\text{ចំណែកមត៌កនៃអ្នកមានផលប្រយោជន៍ពិសេស} = \frac{\text{មត៌កសរុប}}{\text{ចំនួនសន្តតិជន}} - \text{ផលប្រយោជន៍ពិសេស}$$

# ២. ចំណែកមត៌ក

ឧទាហរណ៍ទី១៖




មត៌ក $ ៣.០០០ C ទទួលបាន ផលប្រយោជន៍ពិសេស $ ១.០០០

ចម្លើយ៖ $$C = \frac{3.000 + 1.000}{4} - 1.000\$ = 0$$

$$B=D=E= \frac{3.000 + 1.000}{4} = 1.000\$$$

ដូច្នេះ៖ C=0 , B=D=E= $1000

# ២. ចំណែកមត៌ក

ឧទាហរណ៍ទី២៖




មត៌ក \$ ៣.០០០ C ទទួលបាន ផលប្រយោជន៍ពិសេស \$ 3.000

ចម្លើយ៖ $$C=\frac{3.000 + 3.000}{4} = 1.500\$ -3.000=-1.500$$ (លើសចំណែកមត៌ក)

$$B=D=E=\frac{3.000 + 3.000}{4} = 1.500\$$$

# ២. ចំណែកមត៌ក

ប៉ុន្តែមតិកជាក់ស្តែងមានតែ ៣.០០០ តែប៉ុណ្ណោះ មិនគ្រប់គ្រាន់សម្រាប់សន្តតិជន០៣នាក់ ដែលត្រូវទទួលចំណែកដល់ ១៥០០ ម្នាក់ៗស្មើនឹង ៤.៥០០ នោះទេ ហេតុនេះ ត្រូវសមាមាត្រដោយម្នាក់ៗទទួលបាន ១.០០០ ហើយ C មិនទទួលបានចំណែកមតិកនោះទេ និងយោងតាមមាត្រា ១១៦៣ កថាខណ្ឌទី២ ១១៦៥នៃក្រមរដ្ឋប្បវេណី C ពុំចាំបាច់បង្វិលមកវិញ។ ហេតុនេះ ជាលទ្ធផលចុងក្រោយចំណែកមតិករបស់សន្តតិជនម្នាក់ៗគឺ

B=1.000 ,D=1.000,E=1.000 & C=0

# ២. ចំណែកមត៌ក

តម្លៃនៃប្រទានកម្ម(មាត្រា ១១៦៩)៖ តម្លៃនៃប្រទានកម្មដែលជាមូលដ្ឋាននៃការគណនា ក្នុងករណីអ្នកទទួលផលប្រយោជន៍ពិសេស បានចាត់ចែង ឬបាត់បង់ទ្រព្យដែលទទួលបានដោយប្រទានកម្មមុនពេលចាប់ផ្ដើមសន្តតិកម្ម ជាអាទិ៍ត្រូវយកតម្លៃនៅពេលចាត់ចែង ឬបាត់បង់ទ្រព្យនោះ។ មួយវិញទៀត ប្រសិនបើកម្មវត្ថុនៃប្រទានកម្មជារូបិយវត្ថុអាចមានការផ្លាស់ប្តូរ ប៉ុន្តែមិនមែនជាបញ្ហាសន្តតិកម្មនោះទេ គឺជាបញ្ហានៃការបកស្រាយ ថាតើត្រូវកំណត់តម្លៃនោះនៅពេលចាប់ផ្ដើមសន្តតិកម្ម ឬនៅពេលចាត់ចែងជាអាទិ៍។

# ២. ចំណែកមត៌ក

ឧទាហរណ៍ទី១៖




A មតកជន មុនពេលស្លាប់ បានឱ្យផ្ទះ ដែលមាន តម្លៃ ៣.០០០ ឱ្យទៅC សម្រាប់ចំណងដៃ អាពាហ៍ពិពាហ៍

ក្រោយមក C ក៏បានលក់ផ្ទះនោះ ក្នុងតម្លៃ ៥.០០០ បន្ទាប់ពីលក់ផ្ទះនោះបានមួយឆ្នាំ A ក៏បានស្លាប់

ដូចនេះ តម្លៃប្រទានកម្មដែលជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ៥.០០០។

# ២. ចំណែកមត៌ក

ឧទាហរណ៍ទី២៖




A មតកជន មុនពេលស្លាប់ បានឱ្យផ្ទះ ដែលមាន តម្លៃ ៣.០០០ ឱ្យទៅC សម្រាប់ចំណងដៃ អាពាហ៍ពិពាហ៍

ក្រោយមក ដី-ផ្ទះនោះ បានបាក់ស្រុតចោលទៅទន្លេនៅឆ្នាំ ២០១៩ ហើយតាមការវាយតម្លៃដី-ផ្ទះនោះនៅឆ្នាំ ២០១៩ មានតម្លៃ ២.០០០។ ហើយកន្លងបាន ៣ឆ្នាំ A ក៏ស្លាប់

ដូចនេះ តម្លៃប្រទានកម្មដែលជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ២.០០០។

# ២. ចំណែកមត៌ក

ឧទាហរណ៍ទី៣៖




A មតកជន មុនពេលស្លាប់ បានឱ្យផ្ទះ ដែលមាន តម្លៃ ៣.០០០ ឱ្យទៅC សម្រាប់ចំណងដៃ អាពាហ៍ពិពាហ៍

ក្រោយមក C បានកែសម្រួល និងធ្វើការ្យនានាលើផ្ទះនោះ ដោយចំណាយអស់ ៥.០០០ ហើយបច្ចុប្បន្នផ្ទះ-ដីនោះមានតម្លៃ ១០.០០០។ បន្ទាប់ពីកែផ្ទះនោះ បានមួយឆ្នាំ A ស្លាប់

ដូចនេះ តម្លៃប្រទានកម្មដែលជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ៣.០០០។

# ២. ចំណែកមត៌ក

ឧទាហរណ៍ទី៩៖




A មតកជន មុនពេលស្លាប់ បាន១០.០០០$ ឱ្យទៅ C សម្រាប់ចំណងដៃ អាពាហ៍ពិពាហ៍

ក្រោយមក C បានយកលុយនោះទៅផ្ញើនៅធនាគារតាមរូបភាព fixed deposit សម្រាប់ រយៈពេល០២ឆ្នាំ ដោយទទួលបានការប្រាក់ ៩%/ឆ្នាំ។ ០៣ ឆ្នាំក្រោយមក A ក៏ស្លាប់។

ដូចនេះ តម្លៃប្រទានកម្មដែលជាមូលដ្ឋាននៃការគណនាផលប្រយោជន៍ពិសេសគឺ ១០.០០០។

# ២. ចំណែកមត៌ក

ករណីដែលផលប្រយោជន៍ពិសេសលើសតម្លៃនៃចំណែកមត៌ក(មាត្រា ១១៦៥)៖ ទោះបីជាផលប្រយោជន៍ពិសេសបានទទួលលើសចំណែកមត៌កក៏ដោយ ក៏មិនចាំបាច់បង្វិលសងវិញនោះទេ ហើយចំណែករបស់សន្តតិជនត្រូវសមាមាត្រ។

# ២. ចំណែកមត៌ក

ឧទាហរណ៍៖




មតិក៖ ៧.០០០

C៖ ផ្ទះតម្លៃ៦.០០០«ឱ្យពេលរៀបការ»

D៖ ឱ្យលុយនៅធនគារចំនួន៖ ៨.០០០

មតិកសរុប= ៧.០០០+៨.០០០+៦.០០០= ២១.០០០

ចំណែក C=(២១.០០០៖៣)-៦.០០០= ១.០០០

ចំណែក D=(២១.០០០៖៣)- ៨.០០០= -១.០០០

ចំណែក B=(២១.០០០៖៣)= ៧.០០០

# ២. ចំណែកមត៌ក

នាំឱ្យ D មិនចាំបាច់បង្វិលសងវិញទេ។ មត៌កជាក់ស្តែងមានតែ ៧.០០០ ហេតុនេះ មិនអាចឱ្យទៅ B ៧.០០០ និង C ១.០០០ នោះទេ នាំឱ្យវិធានសមាមាត្រ ត្រូវបានយកមកអនុវត្ត។

ដូចនេះ C=(១.០០០× ៧.០០០)÷៨.០០០ = ៨៧៥

D=(៧.០០០× ៧.០០០)÷៨.០០០ = ៦.១២៥

# ២. ចំណែកមត៌ក

## ២.៣ ភាគនៃវិភាគទាន

ភាគនៃវិភាគទានគឺ ជាប្រភេទមួយនៃការសម្រួលចំណែកមត៌ក ដោយសារនៅក្នុងចំណោមសន្តតិជន មានបុគ្គលម្នាក់ ឬច្រើននាក់បានធ្វើសកម្មភាពថែរក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន ឬថែទាំព្យាបាលមតកជន ឬបានធ្វើសកម្មភាពផ្សេងៗដែលចម្រើនដល់មតកជន។ ភាគនៃវិភាគទាន ជាការបង្រួមចំនួនមត៌ក ដើម្បីឱ្យមានសមភាពជាក់ស្តែងនៅក្នុងចំណោមសន្តតិជន ដោយបុគ្គលណាម្នាក់ ឬច្រើននាក់បានចំណាយសម្រាប់មតកជន មុនពេលសន្តតិកម្មចាប់ផ្តើម។

# ២. ចំណែកមត៌ក

**រូបមន្ត៖** មត៌កសរុប=មត៌កពេលចាប់ផ្តើមសន្តតិកម្ម-ភាគនៃវិភាគទាន

$$\frac{\text{ចំណែកមត៌កនៃអ្នកផ្ញើ}}{\text{ភាគនៃវិភាគទាន}} = \frac{\text{មត៌កជាក់ស្តែង}}{\text{ចំនួនសន្តតិជន}} + \text{ភាគនៃវិភាគទាន}$$

# ២. ចំណែកមត៌ក

ឧទាហរណ៍ទី១៖




មត៌ក $ ៣.០០០ C=១.០០០$

(ភាគនៃវិភាគទាន)

មត៌កជាក់ស្តែង= ៣.០០០ - ១.០០០= ២.០០០

ចម្លើយ៖ $C = \frac{២.000}{4}$ + ១.០០០ =១.៥០០

$B=D=E= \frac{២.000}{4}$ = ៥.OO$

ដូច្នេះ៖ C=១.៥០០ , B=D=E= $៥.០០

# ២. ចំណែកមត៌ក

- ករណីភាគនៃវិភាគទាន>ចំណែកមត៌កដែលមានកំណត់ក្នុងបណ្ដាំមត៌កត្រូវយកបណ្ដាំមត៌កជាគោល យោងតាមមាត្រា ១១៦៦.ក៣

ឧទាហរណ៍៖




មត៌ក \$ ៣.០០០ C=២.០០០\$ (ភាគនៃវិភាគទាន)

ប្រសិនបើបណ្ដាំបានកំណត់ថា C=១.២០០, D=៨០០,E=១.០០០

ដោយសារមតកសាសន៍ ឬបណ្ដាំមត៌កមានអានុភាពជាង ហេតុនេះ ត្រូវអនុវត្តតាមបណ្ដាំនាំឱ្យ C មិនទទួលបានភាគនៃវិភាគនោះទេ។

# ២. ចំណែកមត៌ក

ប្រសិនបើបណ្ដាំបានកំណត់ថា C=៦០០, D=៨០០,E=១.០០០

ដោយសារមតកសាសន៍ ឬបណ្ដាំមត៌កមានអានុភាពជាង ហេតុនេះត្រូវអនុវត្តតាមបណ្ដាំនាំឱ្យ C អាចទទួលបានភាគនៃវិភាគទាននោះតែ ៦០០ ( ៣.០០០-៦០០-៨០០-១០០០=៦០០) ប៉ុណ្ណោះ បន្ទាប់ពីបែងចែងឱ្យ C=៦០០, D=៨០០,E=១.០០០។

# ២. ចំណែកមត៌ក

-ករណីមានភាគនៃវិភាគទាន និងផលប្រយោជន៍ពិសេសក្នុងពេលតែមួយ

ឧទាហរណ៍៖




មត៌ក៖ ៧.០០០

C៖ ផ្ទះតម្លៃ៖៥.០០០«ឱ្យពេលរៀបការ»

D៖ ឱ្យលុយនៅធនាគារចំនួន៖ ១.០០០

B៖ ចំណាយថ្លៃព្យាបាល និងបុណ្យសព៖ ៤.០០០

មត៌កសរុប= ៧.០០០+៥.០០០+១.០០០-៤.០០០= ៩.០០០

ចំណែក C=(៩.០០០៖៣)-៥.០០០= -២.០០០

ចំណែក D=(៩.០០០៖៣)- ១.០០០= ២.០០០

ចំណែក B=(៩.០០០៖៣)+ ៤.០០០= ៧.០០០

# ២. ចំណែកមត៌ក

C មិនចាំបាច់បង្វិលសងវិញនោះទេ។ មត៌កជាក់ស្តែងមានតែ ៧.០០០ ហេតុនេះមិនអាចឱ្យទៅ B ចំនួន ៧.០០០ និង D ចំនួន ២.០០០ នោះទេ នាំឱ្យវិធានសមាមាត្រត្រូវបានយកមកអនុវត្តៈ

ដូចនេះ D=(២.០០០× ៧.០០០)÷៩.០០០ = ១.៥៥៥

B=(៧.០០០× ៧.០០០)÷៩.០០០ = ៥.៤៤៥

# ខ. ការរៀបចំបែងចែកមត៌ក

## ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

- ការបញ្ជាក់ និងការបើកលិខិតមតកសាសន៍ (មាត្រា ១២១៣)៖

មតកសាសន៍ដែលធ្វើឡើងក្រៅពីទម្រង់នៃលិខិតយថាភូត ចាំបាច់ត្រូវធ្វើការពិនិត្យ និងបញ្ជាក់ដោយដាក់សុំទៅតុលាការ។

# ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

លិខិតមតកសាសន៍ ហើយ បានកំណត់ឱ្យ A ជាអ្នកប្រតិបត្តិ




-នៅពេលចាប់ផ្តើមសន្តតិកម្ម A ត្រូវតែដាក់ពាក្យសុំឱ្យធ្វើការពិនិត្យបញ្ជាក់ ទៅតុលាការដោយគ្មានការយឺតយ៉ាវ។

-ចំពោះលិខិតមតកសាសន៍បិទដោយប្រថាប់ត្រា ត្រូវបើកនៅតុលាការ បើបើកនៅក្រៅតុលាការនឹងទទួលពិន័យមិនលើសពី ១.០០០.០០០៛



មតកជន



A អ្នកប្រតិបត្តិមតកសាសន៍

# ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

- ការជ្រើសរើសអ្នកប្រតិបត្តិមតកសាសន៍ (មាត្រា ១២១៨)៖

ក្នុងករណីគ្មានអ្នកប្រតិបត្តិមតកសាសន៍ ឬបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍តាមពាក្យសុំរបស់សន្តតិជន ឬអ្នកមានផលប្រយោជន៍ពាក់ព័ន្ធ។

# ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

ក្នុងករណីដែលគ្មានអ្នកប្រតិបត្តិមតកសាសន៍ ឬបាត់បង់អ្នកប្រតិបត្តិមតកសាសន៍





A អាចដាក់ពាក្យសុំទៅតុលាការដើម្បីឱ្យតុលាការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

A សន្តតិជន

# ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

- មុខងារ និងសិទ្ធិអំណាចរបស់អ្នកប្រតិបត្តិមតកសាសន៍(ជ្រើសតាំងបន្ត)៖

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និងធ្វើសកម្មភាពចាំបាច់ដើម្បីប្រតិបត្តិមតកសាសន៍ ហើយត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ។ លើសពីនេះទៅទៀត បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចជំនួសខ្លួនឡើយ លើកលែងតែមតកជនបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍។

# ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

សូមសងលុយខ្ញុំចំនួន
១.០០០$ ដែលមតក
ជនបានជំពាក់ខ្ញុំ

យល់ព្រម







ម្ចាស់បំណុលរបស់មតកជន

អ្នកប្រតិបត្តិមតកសាសន៍

# ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

- កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍ (មាត្រា ១២២៦) ៖

អ្នកប្រតិបត្តិមតកសាសន៍អាចទទួលបានកម្រៃដែលមានកំណត់នៅក្នុងមតកសាសន៍បាន បើពុំមានក្នុងមតកសាសន៍នោះទេ តុលាការត្រូវកំណត់ចំនួនកម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍។

# ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍



អ្នកប្រតិបត្តិមតកសាសន៍

នៅក្នុង មតកសាសន៍បានកំណត់ពីកម្រៃរបស់ អ្នកប្រតិបត្តិមតកសាសន៍ចំនួន ១.០០០$ សម្រាប់ការងារមួយនេះ។

នៅក្នុងករណី ដែលមតកសាសន៍មិនបានកំណត់កម្រៃ អ្នកប្រតិបត្តិមតកសាសន៍អាចដាក់ពាក្យសុំទៅតុលាការ ឱ្យកំណត់ចំនួនកម្រៃរបស់ខ្លួនបាន។

# ១.ការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃមតកសាសន៍

- សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍ (មាត្រា ១២២៨)៖

សោហ៊ុយពាក់ព័ន្ធនឹងការប្រតិបត្តិមតកសាសន៍ជា បន្ទុកនៃមត៌ក ប៉ុន្តែមិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះទេ។

សោហ៊ុយដើម្បីប្រតិបត្តិមតកសាសន៍

- សោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីពិនិត្យមតកសាសន៍
- សោហ៊ុយធ្វើបញ្ជីសារពើភ័ណ្ឌមត៌ក
- សោហ៊ុយគ្រប់គ្រងមត៌ក
- និងកម្រៃនៃអ្នកប្រតិបត្តិមតកសាសន៍ជាអាទិ៍។

# ២. ការបញ្ជាក់អំពីសន្តតិជន

នៅពេលសន្តតិកម្មចាប់ផ្តើម ទោះបីជាសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍ក៏ដោយ យើងត្រូវធ្វើការផ្ទៀងផ្ទាត់អត្តសញ្ញាណសន្តតិជនឱ្យបានច្បាស់លាស់ ដោយភ្ជាប់ជាមួយនឹងឯកសារបញ្ជាក់អត្តសញ្ញាណ ដែលមានទំនាក់ទំនងញាតិជាមួយនឹងមតកជនដូចជា សំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ សំបុត្រមរណភាព ឬឯកសារអត្រានុកូលដ្ឋានផ្សេងទៀតដែលអាចបញ្ជាក់អំពីទំនាក់ទំនងញាតិ។

# ២. ការបញ្ជាក់អំពីសន្តតិជន

ឯកសារបញ្ជាក់អត្តសញ្ញាណ ដែលមានទំនាក់ទំនងញាតិជាមួយនឹងមតកជន៖








# ៣. ការបញ្ជាក់អំពីកម្មវត្ថុនៃសន្តតិកម្ម

កម្មវត្ថុនៃសន្តតិកម្ម គឺជាទ្រព្យផ្ទាល់របស់មតកជន ដែលអាចជាទ្រព្យដោយឡែក និង១/២នៃទ្រព្យរួមរបស់មតកជន បើមតកជនមានសហព័ទ្ធ។ ទ្រព្យរបស់មតកជនអាចជា ចលនទ្រព្យអចលនទ្រព្យ ប្រាក់នៅក្នុងគណនីយធនាគារ ឬសិទ្ធិលើបំណុលផ្សេងៗទៀត។

តម្លៃនៃកម្មវត្ថុមត៌ក ជាទូទៅត្រូវបានបំលែងជាប្រាក់តាមការសន្មត ដើម្បីងាយស្រួលក្នុងការបែងចែកមត៌ក ជាទូទៅតុលាការកំណត់តម្លៃកម្មវត្ថុមត៌កត្រូវសន្មត នៅពេលសន្តតិកម្មចាប់ផ្តើម។

# ៣. ការបញ្ជាក់អំពីកម្មវត្ថុនៃសន្តតិកម្ម

មតកជនស្លាប់ នៅថ្ងៃទី១៥ ខែ មករាឆ្នាំ២០១៨



ដី



រថយន្ត



លុយនៅធនគារ




គ្រឿងអលង្ការ



តម្លៃជាមូលដ្ឋាននៃទ្រព្យដែលត្រូវបំលែងជាប្រាក់ ត្រូវបានសន្មតនៅថ្ងៃទី១៥ មករា ឆ្នាំ២០១៨ ដីតម្លៃ ១០០.០០០ រថយន្តតម្លៃ ៥០.០០០ គ្រឿងអលង្ការតម្លៃ ៣០.០០០ ហេតុនេះមតិកសរុបមានតម្លៃ ១៨០.០០០។

# ៤. ការបញ្ជាក់អំពីភាតព្វកិច្ច

នៅពេលសន្តតិកម្មចាប់ផ្តើម គប្បីស្រាវជ្រាវ ឬអាចស្វែងយល់ពីបំណុលរបស់មតកជន ដើម្បីឱ្យមានភាពច្បាស់លាស់ ថាតើបំណុលទាំងនោះមានកម្រិតណា ច្រើនជាង ឬតិចជាងទ្រព្យដែលបន្សល់ទុកសម្រាប់ជាមូលដ្ឋានក្នុងការបង្ហាញឆន្ទៈទទួលយកមតិកដោយកម្រិត ឬបោះបង់សន្តតិកម្មជា អាទ៍។

ដើម្បីឱ្យមានភាពច្បាស់លាស់ចំពោះបំណុលរបស់មតកជន គប្បីមានឯកសារបញ្ជាក់បំណុល ដែលអាចជាកិច្ចសន្យាខ្ចីប្រាក់ ជាអាទិ

# ការពិភាក្សា សំនួរ និងចម្លើយ




THANK YOU
for your support!